# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា


**ប្រធានគណៈមេធាវី**

មេធាវី ប៊ុន ហុន

**ក្រុមប្រឹក្សាគណៈមេធាវី**

១-មេធាវី សាំង វណ្ណៈ
២-មេធាវី អ៊ុង ភិរិយា
៣-មេធាវី កែត ឃី
៤-មេធាវី អ៊ីវ ប៉ូលី
៥-មេធាវី ខៀវ សំបូរ
៦-មេធាវី ជា សុកនួន
៧-មេធាវី សាន់ ជួយ
៨-មេធាវី ថាន ផានិត
៩-មេធាវី ជូ ចាន់ធីរ៉ា
១០-មេធាវី កេង សុម៉ាឡា
១១-មេធាវី ម៉ី ឧសភា
១២-មេធាវី សេង សុខឃីម
១៣-មេធាវី លីវ សុវណ្ណា
១៤-មេធាវី ឈីវ តិរម្យ
១៥-មេធាវី សំ សុគង់
១៦-មេធាវី នង មានន្ទ
១៧-មេធាវី អ៊ូ ធីតាពៅ
១៨-មេធាវី លី ពីង
១៩-មេធាវី យឹម វិសុត្រ
២០-មេធាវី លឹម ច័ន្ទលីដា
២១-មេធាវី កែ វិសាល
២២-មេធាវី ហូ លីហួរ
២៣-មេធាវី អ៊ា ពិសី
២៤-មេធាវី ជា ហុងរី
២៥-មេធាវី សៅ កញ្ញា
២៦-មេធាវី ម៉ុន វិមានចំប៉ា
២៧-មេធាវី ឈី សម្បត្តិ


លេខ : ០០៤ /សសគម/១៦

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមករា ឆ្នាំ២០១៦

# សេចក្តីសម្រេច
## ស្តីពី
## ការអនុញ្ញាតឱ្យចូលប្រកបវិជ្ជាជីវៈជាមេធាវីកម្មសិក្សា

## ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **ប៊ុន ហុន** ជាប្រធានគណៈមេធាវីអាណត្តិទី ១០
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៨
- បានឃើញសេចក្តីសម្រេចលេខ ១៧៧/សសគម/១៥ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ របស់គណៈមេធាវី ស្តីពីការអនុញ្ញាតឱ្យលោក **ស៊ុំ ធនសុវណ្ណៈ** ចូលប្រកបវិជ្ជាជីវៈមេធាវី
- បានឃើញកំណត់ហេតុសច្ចាប្រណិធានលេខ ១៣ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៥ របស់សាលាឧទ្ធរណ៍
- យោងតាមសំណើរបស់សាមីខ្លួន
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦។

# **សម្រេច**

**ប្រការ ១.-** លោកមេធាវី **ស៊ុំ ឆនសុវណ្ណៈ** អត្តលេខ **១១៦៤ T** ត្រូវបានអនុញ្ញាតឱ្យធ្វើកម្មសិក្សារយៈពេល ១២(ដប់ពីរ)ខែ ជាមួយលោកមេធាវី **រស់ មុនិន្ទៈ** នៅ **ក្រុមមេធាវី ខេមឡូ** ដែលមានអាសយដ្ឋានស្ថិតនៅ**អគារលេខ ១៣៨ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ** ចាប់ពីថ្ងៃចេញសេចក្តីសម្រេចនេះតទៅ។

**ប្រការ ២.-**
- រាល់ទំនាក់ទំនង និងគ្រប់លិខិតរបស់កម្មសិក្សាការី ដែលធ្វើឡើងក្នុងក្របខ័ណ្ឌប្រកបវិជ្ជាជីវៈរបស់ខ្លួន ត្រូវមានហត្ថលេខាយល់ព្រមពីគ្រូកម្មសិក្សា។
- គ្រប់ការងារកម្មសិក្សារបស់កម្មសិក្សាការី ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងទទួលខុសត្រូវផ្ទាល់របស់គ្រូកម្មសិក្សា។
- ចប់រយៈពេលកម្មសិក្សា កម្មសិក្សាការី ត្រូវធ្វើរបាយការណ៍អំពីលទ្ធផលការងាររបស់ខ្លួន ដោយភ្ជាប់មកជាមួយនូវឯកសារសំអាងទាំងអស់ សម្រាប់ដាក់ជូនក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ និងសម្រេច។

**ប្រការ ៣.-** កម្មសិក្សាការីត្រូវចូលរួមក្នុងវគ្គបណ្តុះបណ្តាលនានារបស់គណៈមេធាវី និងចូលរួមគ្រប់សកម្មភាពដែលចាត់តាំងដោយគណៈមេធាវី។

**ប្រការ ៤.-** កម្មសិក្សាការីត្រូវមានកាតព្វកិច្ចជួយការពារក្តីជូនជនក្រីក្រតាមការចាត់តាំងរបស់គណៈមេធាវី។

**ប្រការ ៥.-** អគ្គលេខាធិការ អគ្គហេរញ្ញិក គ្រូកម្មសិក្សា និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះតាមមុខការរៀងៗខ្លួន៕

ORDRE DES AVOCATS DU ROYAUME DU CAMBODGE

**មេធាវី. ប៊ុន_ហុន**

**ចម្លងជូន:**
- ក្រុមប្រឹក្សាគណៈមេធាវី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ